ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 26-Jul-2012, 11:23
CMS/CFO: Sann Rada

អង្គជំនុំជម្រះតុលាការកំពូល
Supreme Court Chamber
Chambre de la Cour suprême

សំណុំរឿងលេខ: ០០១/១៨ កក្កដា ២០០៧-អ.វ.ត.ក/អ.ជ.ត.ក

Case File/Dossier N°. 001/18-07-2007-ECCC/SC

| | |
|---|---|
| នៅចំពោះមុខ៖ | ចៅក្រម គង់ ស្រីម ប្រធាន |
| | ចៅក្រម Agniezska KLONOWIECKA-MILART |
| | ចៅក្រម សោម សិរីវឌ្ឍ |
| | ចៅក្រម Chandra Nihal Jayasinghe |
| | ចៅក្រម ស៊ិន រិទ្ធ |
| | ចៅក្រម Florence Ndepele MUMBA |
| | ចៅក្រម យ៉ា ណារិន |
| កាលបរិច្ឆេទឯកសារ៖ | ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១២ |
| ភាសាដើម៖ | ខ្មែរ/អង់គ្លេស |
| ចំណាត់ថ្នាក់ឯកសារ៖ | សាធារណៈ |

# សេចក្តីសម្រេចលើគោលការណ៍ណែនាំស្តីពីការធ្វើចំណាត់ថ្នាក់ប្រភេទ ឯកសារឡើងវិញនៅក្នុងសំណុំរឿង

| **<u>ជនជាប់ចោទ៖</u>** | **<u>សហមេធាវីការពារក្ដីជនជាប់ចោទ៖</u>** | **<u>សហព្រះរាជអាជ្ញា៖</u>** |
|---|---|---|
| កាំង ហ្គេកអ៊ាវ | ការ សាវុត្ថ | ជា លាង |
| ហៅ ឌុច | កង ឫទ្ធារី | Andrew CAYLEY |

## I. សេចក្តីផ្តើម

1. អនុលោមតាមមាត្រា ១២ នៃសេចក្តីណែនាំអនុវត្តស្តីពីចំណាត់ប្រភេទ និងការគ្រប់គ្រងព័ត៌មានទាក់ទងនឹងសំណុំរឿង (វិសោធនកម្មលើកទី ១) ("សេចក្តីណែនាំអនុវត្តស្តីពីចំណាត់ប្រភេទឯកសារ") អង្គជំនុំជម្រះតុលាការកំពូល ក្នុងនាមជាការិយាល័យតុលាការចុងក្រោយ ដែលបានទទួលសំណុំឯកសារនៃសំណុំរឿង ០០១/១៨-០៧-២០០៧-អ.វ.ត.ក ("សំណុំឯកសារ នៃសំណុំរឿង ០០១") បានផ្តើមគំនិតធ្វើការពិនិត្យឡើងវិញទៅលើឯកសារទាំងអស់ដែលស្ថិតនៅក្នុងសំណុំឯកសារនៃសំណុំរឿង ០០១ ក្នុងគោលបំណងធ្វើចំណាត់ប្រភេទឡើងវិញទៅលើឯកសារទាំងនោះ តាមដែលអាចធ្វើទៅបាន។

2. នៅថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០១២ ប្រធានអង្គជំនុំជម្រះ បានពន្យល់ពីគោលការណ៍ណែនាំដែលបានស្នើឡើងសម្រាប់ធ្វើចំណាត់ប្រភេទឯកសារឡើងវិញ ហើយនៅពេលនោះ បានស្នើសុំយោបល់នានាពីគ្រប់ភាគី និងអង្គភាពពាក់ព័ន្ធទាំងអស់ ដោយ បានស្នើឲ្យដាក់ជូនយោបល់ឲ្យបានត្រឹមថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១២[1]។ អង្គជំនុំជម្រះ តុលាការកំពូលធ្វើការអនុម័តគោលការណ៍ណែនាំចុងក្រោយនេះ ដោយគោលការណ៍នេះនឹងត្រូវ ប្រើជាមូលដ្ឋានអនុវត្តតាមនៅក្នុងដំណើរការពិនិត្យឡើងវិញទៅលើឯកសារទាំងអស់ ដែលស្ថិត នៅក្នុងសំណុំឯកសារនៃសំណុំរឿង ០០១។ ដើម្បីធ្វើការពិចារណាឲ្យបានត្រឹមត្រូវអំពីហេតុផលទាំងឡាយដែលតម្រូវឲ្យមានការចាត់ប្រភេទឯកសារជាឯកសារសម្ងាត់ ឬសម្ងាត់បំផុតនោះ អង្គជំនុំជម្រះតុលាការកំពូលសូមអញ្ជើញភាគី និងការិយាល័យនានាដែលពាក់ព័ន្ធ សារជាថ្មីទៀត ជាពិសេស ការិយាល័យតុលាការដែលបានសម្រេចពីដំបូងក្នុងការធ្វើចំណាត់ប្រភេទឯកសារទាំងនោះ ឲ្យផ្តល់ការណែនាំដល់អង្គជំនុំជម្រះ ប្រសិនបើនៅមានហេតុផលផ្សេងៗក្នុងការមិនផ្សព្វផ្សាយឯកសារមួយចំនួន ឬមិនផ្សព្វផ្សាយប្រភេទនៃឯកសារផ្សេងៗ នៅក្នុងដំណាក់កាលកិច្ចដំណើរការនីតិវិធីនៅពេលនេះ។

[1] អនុស្សរណៈអន្តរការិយាល័យ កម្មវត្ថុៈ "ការពិនិត្យមើលឡើងវិញនូវឯកសារសម្ងាត់ និងឯកសារសម្ងាត់បំផុតដែលស្ថិតនៅក្នុងសំណុំឯកសារនៃសំណុំរឿង ០០១" ចុះថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០១២ ឯកសារ F30។

## II. ការសង្កេតរបស់ភាគីនានា

3. សហព្រះរាជអាជ្ញាបានដាក់ការសង្កេតរបស់ខ្លួន នៅថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១២[2]។ ជាទូទៅ សហព្រះរាជអាជ្ញាឯកភាពតាមគោលការណ៍ណែនាំ ដែលអង្គជំនុំជម្រះតុលាការកំពូលបានស្នើឡើង និងផ្តល់អនុសាសន៍ថា ជាគោលការណ៍ តម្លាភាពជាអតិបរមាដែលអាចធ្វើបាន និងលទ្ធភាពចូលមើលបាន គួរតែជាគោលបំណងនៃដំណើរការចាត់ប្រភេទឯកសារឡើងវិញនេះ[3]។ ពាក់ព័ន្ធនឹងបញ្ហានេះ សហព្រះរាជអាជ្ញាគាំទ្រ “ឲ្យមានការកោសលុបទូលំទូលាយ ជាជាងរក្សាទុកថាជាប្រភេទហាមឃាត់” ដោយស្នើសុំថា គួរមានការរៀបចំយន្តការសមស្របមួយដើម្បីធានាអំពីការកំណត់ឯកសារដែលមានតែផ្នែកខ្លះនៃឯកសារនោះជាឯកសារសម្ងាត់[4]។ ជាចុងក្រោយ សហព្រះរាជអាជ្ញាបានលើកឡើងថា “ឯកសារសហកាលរបស់កម្ពុជាប្រជាធិបតេយ្យ” ស្ទើរតែទាំងអស់នៅក្នុងសំណុំឯកសារនៃសំណុំរឿង ០០១ គួរតែដកចំណាត់ថ្នាក់ចេញទាំងអស់ ដោយសារតែឯកសារទាំងនោះអាចឲ្យគេរកបានរួចហើយ តាមរយៈឃ្លាំងផ្ទុកឯកសារជាសាធារណៈដទៃទៀត[5]។

4. ពុំទាន់មានភាគីដទៃទៀត ការិយាល័យតុលាការ ឬផ្នែកផ្សេងទៀត បានដាក់ការសង្កេតណាមួយនៅឡើយទេ។ អង្គជំនុំជម្រះតុលាការកំពូលចាត់ទុកការមិនផ្តល់មតិយោបល់លើចំណុចនេះថា អង្គភាពទាំងនេះពុំមានការជំទាស់អ្វីទៅនឹងគោលការណ៍ណែនាំដែលបានស្នើឡើងនោះឡើយ។ អង្គជំនុំជម្រះក៏សូមធ្វើការកត់សម្គាល់ដែរថា ទោះជាយ៉ាងណាក្តី ភាគី ការិយាល័យតុលាការ និងផ្នែកនានា នឹងមានឱកាសបន្ថែមទៀតក្នុងការលើកយោបល់ជូនអង្គជំនុំជម្រះ ពាក់ព័ន្ធនឹងការធ្វើចំណាត់ប្រភេទឯកសារឡើងវិញទៅលើឯកសារជាក់លាក់នានា។

---

[2] ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹង “ការពិនិត្យមើលឡើងវិញនូវឯកសារសម្ងាត់ និងឯកសារសម្ងាត់បំផុតរបស់ ឯ.ឧ គង់ ស្រ៊ីម ដែលស្ថិតនៅក្នុងសំណុំឯកសារនៃសំណុំរឿង ០០១” ចុះថ្ងៃទី ១០ ខែកក្កដា ឆ្នាំ ២០១២ ឯកសារ F30/1 (“ការអង្កេតរបស់ ក.ស.ព”)។

[3] ការអង្កេតរបស់ ក.ស.ព កថាខណ្ឌ ២-៣។

[4] ការអង្កេតរបស់ ក.ស.ព កថាខណ្ឌ ៣-៥។

[5] ការអង្កេតរបស់ ក.ស.ព កថាខណ្ឌ ៦។

## III. **ការពិភាក្សា**

5. អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា ការធ្វើចំណាត់ថ្នាក់លើឯកសារត្រូវធ្វើឡើងដោយធ្វើយ៉ាងណាឲ្យមានតុល្យភាពរវាងតម្រូវការនៃការរក្សាការសម្ងាត់ និងតម្រូវការនៃតម្លាភាព ដែលកើតចេញពីគោលការណ៍ជាសារវន្ត ដែលគ្រប់គ្រងលើនីតិវិធីនៅចំពោះមុខ អ.វ.ត.ក ដោយពិចារណាលើគោលបំណងរបស់តុលាការក្នុងការអប់រំ និងរក្សាកេរ្តិ៍ដំណែល[6]។ ដូច្នេះ អង្គជំនុំជម្រះនេះសូមរំលឹកឡើងវិញថា "ការចែកចាយឲ្យបានទូលំទូលាយនូវសម្ភារៈពាក់ព័ន្ធនឹងកិច្ចដំណើរការនីតិវិធីនៅចំពោះមុខតុលាការ [...] គឺស្របទៅនឹងអាណត្តិរបស់ អ.វ.ត.ក ដែលរួមមានទាំងការចូលរួមចំណែកនៅក្នុងការផ្សះផ្សាជាតិ និងការផ្តល់ឲ្យនូវឯកសារ ដើម្បីគាំទ្រដល់ការស្វែងរកការពិតខាងផ្នែកប្រវត្តិសាស្ត្រដ៏យូរអង្វែងមកហើយ"[7]។ ការចែកចាយភស្តុតាងសំខាន់ៗជាច្រើនដែលមាននៅក្នុងសំណុំរឿង ០០១ អាចជម្រុញឲ្យមាន "កិច្ចពិភាក្សាលើអតីតកាលជាសាធារណៈ និងដោយមិនមានការលាក់លៀម ដោយផ្អែកលើមូលដ្ឋានដ៏រឹងមាំមួយ ដែលជាលទ្ធផល អាចកាត់បន្ថយនូវទស្សនៈនៃការមិនទទួលស្គាល់ ការបំភ្លៃអង្គហេតុ និងការពិតដែលមានតែមួយផ្នែកនោះបាន"[8]។

6. ឯកសារដែលមានតម្លៃជាច្រើននៅក្នុងសំណុំរឿង ត្រូវបានប្រមូលនៅក្នុងអំឡុងពេលដំណើរការកិច្ចស៊ើបសួរ។ ដោយហេតុថា កិច្ចដំណើរការនីតិវិធីនៅក្នុងសំណុំរឿង ០០១ បានបញ្ចប់រួចហើយ ការដកចំណាត់ថ្នាក់ឯកសារដែលពាក់ព័ន្ធកិច្ចស៊ើបសួរលែងមានហានិភ័យជាទូទៅនៃការប៉ះពាល់លើសិទ្ធិរបស់ជនជាប់ចោទ ឬសុចរិតភាពនៃកិច្ចស៊ើបសួរ។ ហេតុដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលសម្រេចថា ជាគោលការណ៍ ឯកសារ ប្រភេទនេះទាំងអស់ត្រូវធ្វើចំណាត់ថ្នាក់ឡើងវិញថាជាឯកសារសាធារណៈ ដូច្នេះត្រូវអនុញ្ញាតឲ្យសាធារណជនទូទៅមានលទ្ធភាពពេញលេញនៅក្នុងការពិនិត្យមើលឯកសារ និងពង្រីកឲ្យ មានតម្លាភាពដល់កម្រិតអតិបរិមា។ នៅក្នុងពេលជាមួយគ្នានេះ ដោយពិចារណាឃើញថា កិច្ចដំណើរការនីតិវិធីនៅចំពោះមុខ អ.វ.ត.ក នៅកំពុងដំណើរការនៅឡើយ ហើយបន្ទាប់ពីបញ្ចប់កិច្ចដំណើរ

[6] *សូមមើល* វិធាន ២១(១) នៃវិធានផ្ទៃក្នុង។ សេចក្តីណែនាំអនុវត្តស្តីពីការធ្វើចំណាត់ប្រភេទឯកសារ មាត្រា ១.២។

[7] សាលដីកា ចុះថ្ងៃទី ៣ ខែ កុម្ភៈ ឆ្នាំ ២០១២ ឯកសារលេខ F28 កថាខណ្ឌ ៧០៨។

[8] *ដូចខាងលើ*។

ការនីតិវិធីនេះ ការសម្ងាត់ចំពោះសំអាងមួយចំនួន អាចនៅតែរក្សាទុក ការពារមួយចំនួនចាំបាច់ តម្រូវឱ្យមាន ដូចដែលមានកំណត់នៅក្នុងគោលការណ៍ណែនាំខាងក្រោម។

7. ដោយពិចារណាលើគោលការណ៍ទូទៅទាំងនេះ និងដោយពិចារណាលើមាត្រា ៤ មាត្រា ៥ និង មាត្រា ៦ នៃសេចក្ដីណែនាំអនុវត្តស្ដីពីការធ្វើចំណាត់ថ្នាក់ឯកសារ អង្គជំនុំជម្រះតុលាការកំពូល អនុវត្តគោលការណ៍ណែនាំដូចតទៅនេះ សម្រាប់ប្រើប្រាស់នៅក្នុងដំណើរការធ្វើចំណាត់ថ្នាក់ ឯកសារឡើងវិញ និងនៅក្នុងការគ្រប់គ្រងលើឯកសារនៅក្នុងសំណុំរឿង ០០១ នាពេលបច្ចុប្បន្ន៖

ក. ឯកសារណាមួយ ឬ ផ្នែកណាមួយនៃឯកសារនេះ ដែលពុំចូលនៅក្នុងកថាខណ្ឌ (ខ) ឬ (គ) ខាងក្រោម ត្រូវធ្វើចំណាត់ថ្នាក់ឡើងវិញថាជាឯកសារសាធារណៈ។

ខ. ឯកសារខាងក្រោម ឬ ផ្នែកណាមួយនៃឯកសារខាងក្រោមដែលត្រូវរក្សាជាឯកសារ សម្ងាត់ដូចជា៖

i. ព័ត៌មានទំនាក់ទំនងលម្អិតរបស់ជនរងគ្រោះ ដែលមិនមែនជាដើមបណ្ដឹង រដ្ឋប្បវេណី រួមទាំងក្នុងករណីដែលព័ត៌មានបែបនេះត្រូវបានសរសេរបញ្ចូលនៅ ក្នុងបណ្ដឹងរបស់ជនរងគ្រោះ។

ii. កំណត់ហេតុជាលាយលក្ខណ៍អក្សរ ប្រតិចារឹក ខ្សែអាត់សម្លេង/រូបភាពនៃ សវនាការ *ជាអសាធារណៈ (in camera)* លើកលែងតែក្នុងករណីសំអាងហេតុ ត្រូវរក្សាការសម្ងាត់លែងមានសុពលភាពទៀត។

iii. ឯកសារទាំងឡាយដែលត្រូវបានដាក់បញ្ចូលនៅក្នុងសំណុំរឿងដែលមាន ស្រាប់ផ្សេងទៀត ហើយត្រូវបានធ្វើចំណាត់ថ្នាក់ថាជាឯកសារសម្ងាត់។

គ. ឯកសារខាងក្រោម ឬផ្នែកណាមួយនៃឯកសារនេះ ដែលត្រូវរក្សាជាឯកសារសម្ងាត់ បំផុតរួមមាន៖

i. សំណើសុំវិធានការការពារ និងឯកសារពាក់ព័ន្ធ។

ii. ឯកសារ និងព័ត៌មានដែលត្រូវមានវិធានការការពារ។

iii. ព័តមានដែលទាក់ទងនឹងសុខភាពរបស់ជនសង្ស័យ ជនត្រូវចោទ និងជនជាប់ ចោទ។

iv. ឯកសារផ្សេងទៀត ដែលនៅតែមានសំអាងហេតុក្នុងការធ្វើចំណាត់ថ្នាក់ថាជាឯកសារសម្ងាត់បំផុត។

ឃ. ប្រសិនបើឯកសារណាមួយមានផ្នែកមួយដែលគួរជាឯកសារសាធារណៈ ឬផ្នែកណាមួយនៃឯកសារដែលគួរត្រូវបានធ្វើចំណាត់ថ្នាក់ឯកសារថាជាសម្ងាត់ ឬសម្ងាត់បំផុតនោះ មាត្រា ៣.៣ នៃសេចក្តីណែនាំអនុវត្តស្តីពីការធ្វើចំណាត់ប្រភេទ ត្រូវយកមកអនុវត្ត។

ង. ឯកសារសាធារណៈមិនត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈនោះទេ ប្រសិនបើឯកសារទាំងនោះ (ក) ត្រូវបានការពារដោយច្បាប់កម្មសិទ្ធិបញ្ញាជាធរមាន ឬ (ខ) "ត្រូវមានការយល់ព្រមពីតតិយជន ដែលបានហាមឃាត់ការផ្សព្វផ្សាយ [...] លើកលែងតែមានការអនុញ្ញាតពីតតិយជននេះ"[9]។

ច. អង្គជំនុំជម្រះតុលាការកំពូលនៅតែមានយុត្តាធិការនៅក្នុងការដាក់ទណ្ឌកម្ម ស្របតាមវិធានផ្ទៃក្នុង ចំពោះការលាតត្រដាងព័ត៌មានដែលត្រូវបានធ្វើចំណាត់ប្រភេទថាសម្ងាត់ដោយគ្មានការអនុញ្ញាត។

ឆ. ភាគីពាក់ព័ន្ធ រួមទាំង ការិយាល័យសហព្រះរាជអាជ្ញា អង្គការគាំពារការការពារក្តី ដែលតំណាងឲ្យជនជាប់ចោទនៅក្នុងសំណុំរឿង ០០១ អង្គភាពគាំពារជនរងគ្រោះ ដែលតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណី អង្គភាពគាំពារសាក្សី និងអ្នកជំនាញ ឬ ផ្នែកកិច្ចការសាធារណៈ អាចស្នើសុំឲ្យធ្វើចំណាត់ប្រភេទឯកសារណាមួយឡើងវិញ ដែលឯកសារទាំងនោះនៅរក្សាចំណាត់ថ្នាក់របស់ខ្លួនជាឯកសារសម្ងាត់ ឬសម្ងាត់បំផុត ក្រោយពីបានបញ្ចប់នីតិវិធីធ្វើចំណាត់ប្រភេទឡើងវិញ។ នៅក្នុងករណីបែបនេះ ភាគីដែលពាក់ព័ន្ធត្រូវបង្ហាញពីកាលៈទេសៈដែលមានការប្រែប្រួល ដែលផ្តល់យុត្តិកម្មចំពោះការធ្វើចំណាត់ប្រភេទឯកសារនោះឡើងវិញ។

[9] សេចក្តីណែនាំអនុវត្តស្តីពីការធ្វើចំណាត់ប្រភេទឯកសារ មាត្រា ១២.៣។

8. សេចក្ដីសម្រេចនេះ[10] ភ្ជាប់ជាមួយនឹងតារាងឯកសារសម្ងាត់បំផុត ដែលអង្គភាពបណ្ណសារបានចងក្រង ដោយបានកំណត់អត្តសញ្ញាណឯកសារនៅក្នុងសំណុំរឿង ០០១ ដែលមិនស្ថិតនៅក្នុងសំណុំរឿងដែលបន្តមាននៅចំពោះមុខ អ.វ.ត.ក។ អង្គជំនុំជម្រះតុលាការកំពូលសូមអញ្ជើញគ្រប់ភាគី និងការិយាល័យពាក់ព័ន្ធទាំងអស់ ឲ្យផ្ដល់យោបល់ថាតើ ឬថាខ្លួនមានហេតុផលអ្វី ដែលយល់ឃើញថា ឯកសារជាក់លាក់ណាមួយ ឬប្រភេទឯកសារទូទៅណានោះ គួររក្សាចំណាត់ថ្នាក់បច្ចុប្បន្នរបស់ខ្លួន។ ដើម្បីផ្ដល់ពេលវេលាគ្រប់គ្រាន់ដើម្បីផ្ដល់យោបល់លើចំណុចនេះ អង្គជំនុំជម្រះនឹងមិនធ្វើចំណាត់ប្រភេទឯកសារណាមួយឡើងវិញក្នុងរយៈពេល ២០ ថ្ងៃ បន្ទាប់ពីចេញសេចក្ដីសម្រេចនេះ។

9. សាធារណជននឹងត្រូវបានជូនដំណឹងឲ្យបានទាន់ពេលវេលាអំពីការបញ្ចប់ដំណើរការធ្វើចំណាត់ប្រភេទឯកសារឡើងវិញនេះ។

## IV. ផ្នែកសម្រេចសេចក្ដី

យោងតាមសំអាងហេតុខាងលើ **អង្គជំនុំជម្រះតុលាការកំពូលសម្រេចៈ**

**អនុម័ត**គោលការណ៍ណែនាំទូទៅស្ដីពីការធ្វើចំណាត់ប្រភេទឯកសារឡើងវិញដូចបានរៀបរាប់ខាងលើ[11]។

**អញ្ជើញ**ភាគី និងការិយាល័យពាក់ព័ន្ធ ផ្ដល់យោបល់ត្រឹមថ្ងៃទី ១៥ ខែ សីហា ២០១២ លើឯកសារទាំងឡាយណាដែលមាននៅក្នុងបញ្ជីឯកសារសម្ងាត់បំផុតដែលដាក់ភ្ជាប់មកជាមួយនេះ។

**រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ២០១២**

**ប្រធានអង្គជំនុំជម្រះតុលាការកំពូល**

**គង់ ស្រីម**

[10] កំណត់ហេតុសម្ងាត់នៃសំណុំរឿង ០០១ មិនមានស្ថិតក្នុងសំណុំរឿង ០០២, ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១២, ឯកសារលេខ F30/2.1។

[11] *សូមមើល ចំណុចខាងលើ* កថាខណ្ឌ ៧។